ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 04 / 2015
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ឯកសារ E337/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៥

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ស្តីពីឯកសារពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីក្រុមមេធាវីការពារក្តី នួន ជា ដែលសុំដាក់ឯកសារចំនួន ៥ ចូលទៅក្នុងសំណុំរឿង ("សំណើសុំ") និងសុំបញ្ចូលឯកសារទាំងនេះធ្វើជាភស្តុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E337 កថាខណ្ឌ ៥ កថាខណ្ឌ ៩ និងទំព័រ ៦)។ ឯកសារទាំងនោះរួមមាន៖ (១) សៀវភៅ ដែលនិពន្ធដោយដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ដែលមានចំណងជើងថា "ក្រោមដំណក់ទឹកភ្លៀង" (២) សេចក្តីប្រកាសព័ត៌មានរបស់សមាគមជនរងគ្រោះរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជា (៣) អត្ថបទនៅក្នុងគេហទំព័រ "វិទ្យុជាតិ" (៤) អត្ថបទកាសែត "ភ្នំពេញប៉ុស្តិ៍" ប្រចាំសប្តាហ៍ និង (៥) វិចារលើសៀវភៅ "ក្រោមដំណក់ទឹកភ្លៀង"[១]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា អង្គជំនុំជម្រះគួរច្រានចោលសំណើសុំនេះដោយផ្អែកលើមូលដ្ឋានថា សំណើសុំនេះពុំបានដាក់ឱ្យបានទាន់ពេលវេលា ពុំបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៨៧(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយសំណើសុំនេះពុំមែនធ្វើឡើងដើម្បី

---

[១] ឯកសារទាំងនេះ បច្ចុប្បន្នមាននៅក្នុងប្រព័ន្ធផ្ទុកសម្ភារៈរួម និងមានលេខ ERN ដូចខាងក្រោមនេះ៖ (១) 01058323-01058332 (២) 01058310-01058316 (៣) 01058317-01058319 (៤) 01058320 និង (៥) 01058321-01058322។

ផលប្រយោជន៍នៃយុត្តិធម៌នោះទេ (ឯកសារ E337/1 កថាខណ្ឌ ១ កថាខណ្ឌ ៥-៨)។ សហ-ព្រះរាជអាជ្ញាស្នើសុំឱ្យអង្គ-ជំនុំជម្រះច្រានចោលការទទួលយកឯកសារលេខ ១ លេខ ២ លេខ ៣ និងលេខ ៥ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពីព្រោះថាឯកសារលេខ ១ និងលេខ ៥ នឹងទាមទារពេលវេលាច្រើនដើម្បីវែកញែករឿងពិតជាមួយនឹងរឿងប្រឌិត ចំណែកឯកសារលេខ ២ និងលេខ ៣ នឹងពុំអាចផ្ដាញ់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬ ពុំមានតម្លៃអ្វីក្នុងការបញ្ជាក់ការពិត ឡើយ (ឯកសារ E337/2 កថាខណ្ឌ ៦-៧ កថាខណ្ឌ ១០)។ សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកឯកសារលេខ ៤ ពោលគឺ អត្ថបទពីកាសែត "ភ្នំពេញប៉ុស្តិ៍" ប៉ុន្តែសន្និដ្ឋានថា ដើម បណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី ពុំគួរចាំបាច់ត្រូវកោះហៅមកវិញដើម្បីសួរដេញដោលបន្ថែមលើឯកសារនេះទេ ដោយសារក្រុមមេធាវីការពារក្ដីឱ្យ នួន ជា បដិសេធដោយចេតនាពុំគោរពតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ (ឯកសារ E337/2 កថាខណ្ឌ ២ កថាខណ្ឌ ៨ កថាខណ្ឌ ១០)។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះហាមឃាត់ក្រុមមេធាវីការពារក្ដីក្នុងការតាំងសំណួរទៅសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្អែកលើឯកសារទាំងនេះ ដែលពុំបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីផ្សេងទៀតនៅឡើយ (ឯកសារ E337/2 កថាខណ្ឌ ១ កថាខណ្ឌ ៣ កថាខណ្ឌ ៥ កថាខណ្ឌ ១០)។

២. ក្រុមមេធាវីការពារក្ដី នួន ជា សន្និដ្ឋានថា យោងតាមការពិនិត្យ*មើលបឋម* ឯកសារទាំងនេះហាក់ដូចជាផ្ទុយនឹងសក្ខីកម្មរបស់ អ៊ុំ សុផានី នៅក្នុងពេលជំនុំជម្រះពីព្រោះ ឯកសារ ទាំងនេះបង្ហាញថា លោកស្រីបានថ្លែង និងបានគាំទ្រសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដែលបញ្ជាក់ថាលោកស្រីធ្លាប់បានគេបង្ខំឱ្យរៀបការជាមួយនឹងកម្មាភិបាលខ្មែរក្រហមមួយរូប។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្ដីសន្និដ្ឋានថា ឯកសារទាំងនេះគួរទទួលយកបានដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ពីព្រោះឯកសារទាំងនេះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសក្ខីកម្មរបស់ អ៊ុំ សុផានី ព្រមទាំងប៉ះពាល់លើភាពអាចជឿជាក់បានលើសក្ខីកម្មរបស់លោកស្រី ដូច្នេះឯកសារទាំងនេះអាចជួយបញ្ជាក់ការពិតបាន (ឯកសារ E337 កថាខណ្ឌ ៦ កថាខណ្ឌ ៨)។

៣. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មីទាំងឡាយណាដែលខ្លួនយល់ឃើញថាអាចបញ្ជាក់ការពិត។ អង្គជំនុំជម្រះនឹងសម្រេចលើខ្លឹមសារនៃសំណើសុំឱ្យទទួលយកភស្តុតាងថ្មីអនុលោមតាមលក្ខខណ្ឌនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏បានតម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបំពេញតាមលក្ខខណ្ឌទាំងនេះដោយត្រូវដាក់សេចក្ដីសន្និដ្ឋាន ដែលមាន

01086129



សម្អាងហេតុត្រឹមត្រូវ។ ភាគីស្នើសុំត្រូវធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា ភស្តុតាងដែលបានស្នើសុំពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ ឬ មិនអាចរកឃើញនាពេលមុន បើទោះជាបានខិតខំប្រឹងប្រែងរកយ៉ាងសមស្របរួចហើយក៏ដោយ។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញថា ជាធម្មតា ភាគីត្រូវដាក់សំណើសុំរួមអនុលោមតាម វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដើម្បីស្នើសុំឱ្យទទួលយកឯកសារថ្មីទាំងអស់ក្នុងចេតនាដើម្បី យកមកប្រើប្រាស់ក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សីឱ្យបានយ៉ាងហោចណាស់ ២ សប្តាហ៍ មុនពេលសាក្សីគ្រោងនឹងមកបង្ហាញខ្លួន (ឯកសារ E 276/2 យោងលើឯកសារ E218 កថាខណ្ឌ ២២)។

៤. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា អ៊ុំ សុផានី ពុំបានចោទប្រកាន់ទាំងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ទាំងនៅក្នុងពេលលោកស្រីបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះថា លោកស្រីត្រូវបានគេបង្ខំឱ្យរៀបការនោះឡើយ[២]។ ករណីដែលថា ក្រុមមេធាវីការពារក្តីមានបំណងផ្អែកលើឯកសារទាំងនេះ ដើម្បីផ្ចាញ់លើភាពអាចជឿជាក់បានរបស់លោកស្រីនោះ អង្គជំនុំជម្រះយល់ឃើញថា ក្រុមមេធាវីការពារក្តីពុំបានបង្ហាញថា អ៊ុំ សុផានី បានលើកឡើងថា លោកស្រីត្រូវបានគេបង្ខំឱ្យរៀបការនោះឡើយ។ ឯកសារលេខ ១ គឺជារឿងប្រលោមលោកដោយផ្អែកលើរឿងរ៉ាវអំពីជីវិតរបស់លោកស្រីដោយបានពិពណ៌នាតួអង្គ ដែលឈ្មោះរបស់តួអង្គទាំងនេះពុំមែនជាឈ្មោះរបស់អ្នកនិពន្ធ ឬ សាច់ញាតិរបស់អ្នកនិពន្ធ ឡើយ[៣]។ អ៊ុំ សុផានី បានបញ្ជាក់លើបញ្ហានេះនៅក្នុងសវនាការរួចហើយនៅពេលលោកស្រីបានផ្តល់សក្ខីកម្មថា សៀវភៅនេះពុំមែនរៀបរាប់ពីជីវប្រវត្តិរបស់លោកស្រីទាំងស្រុងតែ

---

[២] សូមមើល របាយការណ៍របស់អង្គភាពជនរងគ្រោះស្តីពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D22/3248/1 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១០។ ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី 09-VU-03554 ឯកសារ E307/6.1.11 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤ ដែលលោកស្រីបានឃើញផ្ទាល់ភ្នែក "សាច់ថ្លៃ" របស់លោកស្រី ព្រមទាំងគូរផ្សេងទៀតត្រូវបានគេបង្ខំឱ្យរៀបការ ប៉ុន្តែលោកស្រីពុំបានបញ្ជាក់ថា លោកស្រីខ្លួនឯងត្រូវបានគេបង្ខំឱ្យរៀបការដែរ ឬក៏យ៉ាងណានោះទេ។ សូមមើលផងដែរ ឯកសារ E337/1 កថាខណ្ឌ ៨ និងឯកសារ E337/2 កថាខណ្ឌ ៧។

[៣] សៀវភៅនេះគឺជា "រឿងប្រលោមលោក" (សូមមើលសៀវភៅចំណងជើងថា "ក្រោមដំណក់ទឹកភ្លៀង"ប្រព័ន្ធផ្ទុកសម្ភារៈឯកសាររួម ERN (ភាសាអង់គ្លេស) 01058328-01058330 ទំព័រ ១ ទំព័រ ៣ ទំព័រ ៤) ហើយសៀវភៅនេះបានពិពណ៌នាអ្នកនិពន្ធថា ជា "អ្នកនិពន្ធដែលល្បីឈ្មោះ (...) ក្នុងការនិពន្ធរឿងប្រឌិតបែបប្រវត្តិសាស្ត្រ"។ បុព្វកថាសរសេរថា៖ "វា [សៀវភៅ] រៀបរាប់រឿងរ៉ាវអំពីជីវិតរបស់ខ្ញុំ"។

ម្តងនោះទេ[6]។ ដោយសារពុំឃើញមានភាពផ្ទុយគ្នាណាមួយនោះ សៀវភៅនេះពុំអាចយកមកផ្លាញ់ភាពអាចជឿជាក់បានលើលោកស្រីនោះទេ។ ឯកសារលេខ ៥ និងលេខ ២ សង្ខេបលើខ្លឹមសារ និងមានចំណុចដកស្រង់ពីរឿងប្រលោមលោកនេះ[7]។ ចំពោះឯកសារលេខ ៣ និងលេខ ៤ អត្ថបទព័ត៌មានទាំងនេះគឺជាប្រភពបន្ទាប់បន្សំនៃរឿងរ៉ាវរបស់ អ៊ុំ សុផានី និងពុំបានបញ្ជាក់ថា លោកស្រីបានគាំទ្រសេចក្តីថ្លែងការណ៍ទាំងឡាយដែលមាននៅក្នុងនោះឡើយ។ ដោយហេតុថា ឯកសារទាំងនេះពុំបង្ហាញនូវភាពផ្ទុយគ្នាដែលអាចកើតមានជាមួយនឹងសក្ខីកម្មនៅក្នុងតុលាការរបស់លោកស្រី ឯកសារទាំងនេះពុំសមស្របក្នុងការបង្ហាញអង្គហេតុដែលក្រុមមេធាវីការពារក្តីអះអាងថា នឹងបង្ហាញឱ្យឃើញនោះទេ (*សូមមើល ឧ.* ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១១៥-១០៣។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២១-២២)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ឯកសារទាំងប្រាំដែលបានស្នើសុំឱ្យទទួលយកទាំងនេះ ពុំអាចជួយបញ្ជាក់ការពិតនៅក្នុងអត្ថន័យនៃវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង បានឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើសុំនេះ។

៥. អនុស្សារណៈនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E337។

---

[6] សូមមើល ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ (អ៊ុំ សុផានី) ទំព័រ ៨៩។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ (អ៊ុំ សុផានី) ទំព័រ ២៣-២៥)។

[7] សូមមើល ឯកសារលេខ ២ ទំព័រ ៤។